អគ្គមគ្គសមង្គីនំ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តេសំ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ បច្ឆិមចិត្តសមង្គីនំ តេសំ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។

(១៤២) យត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។ យត្ថ វា បន អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។

(១៤៣) យត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ ឧប្បជ្ជិស្សន្តិ ។ យត្ថ វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ នត្ថិ ។

(១៤៤) យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ ឧប្បជ្ជិស្សន្តិ ។

ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វ ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណានោះ នឹងមិនកើតឡើងទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វ អ្នកព្រមព្រៀងដោយបឋមចិត្តនោះ ក៏នឹងមិនកើតឡើងទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ អើ ។

(១៤២) ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

(១៤៣) ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

(១៤៤) ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។

យត្ថ វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ នត្ថិ ។

(១៦៥) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។ យស្ស វា បន យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ(១) ។ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ(១) អគ្គមគ្គសមង្គីនំ អរហន្តានំ អសញ្ញសត្តានំ តេសំ តត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។

(១៦៦) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ(១) ។ អគ្គមគ្គសមង្គីនំ អរហន្តានំ អសញ្ញសត្តានំ តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ(១)

---

១ ឱ. ឯត្ថន្តរេ ចតុវោការេ បញ្ចវោការេតិ ទិស្សន្តិ ។

ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសល-ធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

(១៨៥) ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ ដែលជាសត្វនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា នឹងមិនកើតឡើង ក្នុងទីនោះទេ តែពួកកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងទេ ទាំងពួកកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។

(១៨៦) ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ

បឋមចិត្តសមង្គីនំ តេសំ តត្ថ កុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។

(១៤៧) យស្ស យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ អគ្គមគ្គសមង្គីនំ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ អសញ្ញសត្តានំ តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ បឋមចិត្តសមង្គីនំ តេសំ តត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ អព្យាកតា ច ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។

(១៤៨) យស្ស កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អកុសលា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។

ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វ អ្នកព្រមព្រៀងដោយបច្ឆិម-ចិត្តនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

(១៤៧) ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វ អ្នកព្រមព្រៀងដោយបច្ឆិម-ចិត្តនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

(១៤៨) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

យស្ស វា បន អកុសលា ធម្មា ឧប្បជ្ជិត្ថ តស្ស កុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អកុសលា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ អកុសលា ច ធម្មា ឧប្បជ្ជិត្ថ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៤៩) យស្ស កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។ យស្ស វា បន អព្យាកតា ធម្មា ឧប្បជ្ជិត្ថ តស្ស កុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អព្យាកតា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ អព្យាកតា ច ធម្មា ឧប្បជ្ជិត្ថ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៥០) យស្ស អកុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។

ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈ នៃចិត្ត ដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៤៩) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៥០) ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

យស្ស វា បន អព្យាកតា ធម្មា ឧប្បជ្ជិត្ថ តស្ស អកុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អព្យាកតា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ អកុសលា ធម្មា ឧប្បជ្ជន្តិ អកុសលានំ ឧប្បាទក្ខណេ តេសំ អព្យាកតា ច ធម្មា ឧប្បជ្ជិត្ថ អកុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៨១) យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ ។ បេ ។

(១៨២) យស្ស យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។ យស្ស វា បន យត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ[១] ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ[២] កុសលានំ ឧប្បាទក្ខណេ តេសំ តត្ថ អកុសលា ច ធម្មា ឧប្បជ្ជិត្ថ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

---

១ ឱ. អយំ បាឋោ សព្វត្ថ ន ទិស្សតិ ។ ឯត្ថ បទេ បន ចតុវោការេ បញ្ចវោការេតិ យេភុយ្យេន ទិស្សន្តិយេវ ។ ២ ឱ. ឯត្ថន្តរេ ចតុវោការេ បញ្ចវោការេតិ សព្វត្ថ ទិស្សន្តិយេវ ។

ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែអកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈ នៃអកុសលទាំងឡាយ ទាំងពួកអកុសល-លធម៌ ក៏កើតឡើងដែរ ។

(១៩១) ពួកកុសលធម៌ កើតឡើង ក្នុងទីណា ។ បេ ។

(១៩២) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជន ទាំងអស់នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៨៣) យស្ស យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ឧប្បជ្ជិត្ថ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ តត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិត្ថ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៨៤) យស្ស យត្ថ អកុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ឧប្បជ្ជិត្ថ តស្ស តត្ថ អកុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជន្តិ អកុសលានំ ឧប្បាទក្ខណេ តេសំ តត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិត្ថ

(១៨៣) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្ត ដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៨៤) ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្ត ដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ

អកុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៥៥) យស្ស កុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស អកុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។ យស្ស វា បន អកុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ នត្ថិ ។

(១៥៦) យស្ស កុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។ យស្ស វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថ តស្ស កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ នត្ថិ ។

(១៥៧) យស្ស អកុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។ យស្ស វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថ តស្ស អកុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ នត្ថិ ។

(១៥៨) យត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ ។ បេ ។

(១៥៩) យស្ស យត្ថ កុសលា ធម្មា ន ឧប្ប-ជ្ជន្តិ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។

នៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

(១៩៥) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

(១៩៦) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

(១៩៧) ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

(១៩៨) ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ។ បេ ។

(១៩៩) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។

សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិត្ថ សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេ(១) អសញ្ញសត្តានំ តេសំ តត្ថ កុសលា ច ធម្មា ន ឧប្បជ្ជន្តិ អកុសលា ច ធម្មា ន ឧប្បជ្ជិត្ថ ។ យស្ស វា បន យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អាមន្តា ។

(១៦០) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថ សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ កុសលា ច ធម្មា ន ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិត្ថ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អាមន្តា ។

---

១ ឱ. ទុតិយេ ចិត្តេ វត្តមានេតិ ឯត្ថ ឧប្បត្តិចិត្តស្ស ភង្គក្ខណេតិ ទិស្សន្តិយេវ ។

ពួកកុសលធម៌ របស់ពួកសត្វ ទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន កាលបើចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះ ឬ ។ អើ ។

(១៦០) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅ កាន់សុទ្ធាវាស មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

(១៦១) យស្ស យត្ថ អកុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថ សុទ្ធាវាសំ ឧបបជ្ជន្តានំ តេសំ តត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិត្ថ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិត្ថ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អាមន្តា ។

(១៦២) យស្ស កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អកុសលា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អគ្គមគ្គស្ស ឧប្បាទក្ខណេ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ឧប្បាទក្ខណេ តេសំ កុសលា ធម្មា ឧប្បជ្ជន្តិ នោ ច តេសំ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ កុសលានំ ឧប្បាទក្ខណេ តេសំ កុសលា ច ធម្មា ឧប្បជ្ជន្តិ អកុសលា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ឧប្បជ្ជន្តីតិ ។

[ ១៦១ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅ កាន់សុទ្ធាវាស មិនកើតឡើង ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៦២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកជន នឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា ក្នុងឧប្បាទក្ខណៈ នៃមគ្គដ៏ប្រសើរ ពួកកុសលធម៌ របស់ពួកជននោះ កើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកជននោះ កើតឡើង ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។

សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ អកុសលា ច ធម្មា ឧប្បជ្ជន្តិ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៦៣) យស្ស កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។ យស្ស វា បន អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៦៤) យស្ស អកុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។

ពួកអកុសលធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៦៣) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៦៤) ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។

យស្ស វា បន អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស អកុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ អកុសលា ធម្មា ឧប្បជ្ជន្តិ អកុសលានំ ឧប្បាទក្ខណេ តេសំ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ អកុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៦៥) យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ ។ បេ ។

(១៦៦) យស្ស យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តីតិ(១) ។ អគ្គមគ្គស្ស ឧប្បាទក្ខណេ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ឧប្បាទក្ខណេ តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ(២) កុសលានំ ឧប្បាទក្ខណេ តេសំ តត្ថ កុសលា ច ធម្មា ឧប្បជ្ជន្តិ អកុសលា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជន្តីតិ ។

---

១-២ ឱ. ឯត្ថន្តរេ បតុវោការេ បញ្ចវោការេតិ ទិស្សន្តិ ។

ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្ត ដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

(១៦៥) ពួកកុសលធម៌ កើតឡើង ក្នុងទីណា ។ បេ ។

(១៦៦) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា ក្នុងឧប្បាទក្ខណៈ នៃមគ្គដ៏ប្រសើរ កើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ទើបកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។

សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ តត្ថ អកុសលា ច ធម្មា ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៦៧) យស្ស យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ កុសលានំ ឧប្បាទក្ខណេ តេសំ តត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៦៨) យស្ស យត្ថ អកុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អាមន្តា ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អកុសលា ធម្មា ឧប្បជ្ជន្តីតិ ។

ពួកអកុសលធម៌ របស់ពួកជន ទាំងអស់នោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៦៧) ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

(១៦៨) ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។

សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្ត-
ចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ
អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ
អកុសលា ធម្មា ឧប្បជ្ជន្តិ អកុសលានំ ឧប្បាទក្ខ-
ណេ តេសំ តត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ
អកុសលា ច ធម្មា ឧប្បជ្ជន្តិ ។

(១៦៩) យស្ស កុសលា ធម្មា ន ឧប្បជ្ជន្តិ
តស្ស អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សព្វេសំ
ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បា-
ទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ
កុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ អកុ-
សលា ធម្មា ន ឧប្បជ្ជិស្សន្តិ អគ្គមគ្គស្ស ភង្គក្ខណេ
អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិល-
ភិស្សន្តិ តស្ស ចិត្តស្ស ភង្គក្ខណេ តេសំ កុសលា
ច ធម្មា ន ឧប្បជ្ជន្តិ អកុសលា ច ធម្មា ន ឧប្ប-
ជ្ជិស្សន្តិ ។ យស្ស វា បន អកុសលា ធម្មា ន
ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។

ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

(១៦៩) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងដែរឬ ។ ពួកកុសលធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈ នៃមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា នោះ មិនកើតឡើង ក្នុងភង្គក្ខណៈ នៃចិត្តនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងទេឬ ។

អគ្គមគ្គស្ស ឧប្បាទក្ខណេ យស្ស ចិត្តស្ស អនន្តរា
អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ឧប្បាទក្ខណេ
តេសំ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ
កុសលា ធម្មា ន ឧប្បជ្ជន្តិ អគ្គមគ្គស្ស ភង្គក្ខណេ
អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិល-
ភិស្សន្តិ តស្ស ចិត្តស្ស ភង្គក្ខណេ តេសំ អកុសលា
ច ធម្មា ន ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ន
ឧប្បជ្ជន្តិ ។

(១៧០) យស្ស កុសលា ធម្មា ន ឧប្បជ្ជន្តិ
តស្ស អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សព្វេសំ
ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បា-
ទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ
កុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ អព្យា-
កតា ធម្មា ន ឧប្បជ្ជិស្សន្តិ បច្ឆិមចិត្តសមង្គីនំ តេសំ
កុសលា ច ធម្មា ន ឧប្បជ្ជន្តិ អព្យាកតា ច
ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អព្យាកតា
ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ន
ឧប្បជ្ជន្តីតិ ។ អាមន្តា ។

(១៧១) យស្ស អកុសលា ធម្មា ន ឧប្បជ្ជន្តិ

ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា ក្នុងឧប្បាទក្ខណៈ នៃមគ្គដ៏ប្រសើរ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តនោះទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈ នៃមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនកើតឡើង ក្នុងភង្គក្ខណៈ នៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

(១៧០) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើងទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។

(១៧១) ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង

តស្ស អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អកុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ បច្ឆិមចិត្តសមង្គីនំ តេសំ អកុសលា ច ធម្មា ន ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស អកុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អាមន្តា ។

(១៧២) យត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ ។បេ។

(១៧៣) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ កុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ អគ្គមគ្គស្ស ភង្គក្ខណេ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ភង្គក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ កុសលា ច ធម្មា ន ឧប្បជ្ជន្តិ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។

ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើងទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងទេឬ ។ អើ ។

(១៧២) ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ។ បេ ។

(១៧៣) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជន ទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈ នៃមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបានទទួលមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងរបស់ពួកអសញ្ញសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃចិត្តនោះ ទាំងពួកអកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។

យស្ស វា បន យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អគ្គមគ្គស្ស ឧប្បាទក្ខណេ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ឧប្បាទក្ខណេ តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ អគ្គមគ្គស្ស ភង្គក្ខណេ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ភង្គក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ន ឧប្បជ្ជន្តិ ។

(១៧៨) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ បច្ឆិមចិត្តសមង្គីនំ តេសំ តត្ថ កុសលា ច ធម្មា ន ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អាមន្តា ។

ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ទំនងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលទំនងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា ក្នុងឧប្បាទក្ខណៈ នៃមគ្គដ៏ប្រសើរ ទំនងមិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈ នៃមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលទំនងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា និងរបស់ពួកអសញ្ញ-សត្តនោះ ទំនងមិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

(១៧៤) ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ ទំនងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្ត ទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្តនោះ ទំនងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្ត អ្នកព្រមព្រៀងដោយបច្ឆិមចិត្ត នោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏ទំនងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ទំនងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

(១៧៥) យស្ស យត្ថ អកុសលា ធម្មា ន ឧប្បជ្ជន្តិ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សព្វេសំ ចិត្តស្ស ភង្គក្ខណេ អកុសលវិប្បយុត្តចិត្តស្ស ឧប្បាទក្ខណេ អសញ្ញសត្តានំ តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ បច្ឆិមចិត្តសមង្គីនំ តេសំ តត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជន្តីតិ ។ អាមន្តា ។

(១៧៦) យស្ស កុសលា ធម្មា ឧប្បជ្ជិត្ថ តស្ស អកុសលា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ អគ្គមគ្គសមង្គីនំ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តេសំ កុសលា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ តេសំ កុសលា ច ធម្មា ឧប្បជ្ជិត្ថ អកុសលា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ឧប្បជ្ជិត្ថាតិ ។ អាមន្តា ។

ធម្មយមកៈ បវត្តិវារៈ ឧប្បាទវារៈ

(១៧៥) ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វ ទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ នៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

(១៧៦) ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា នោះ ធ្លាប់កើតឡើងហើយ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

(១៧៧) យស្ស កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ បច្ឆិមចិត្តសមង្គីនំ តេសំ កុសលា ធម្មា ឧប្បជ្ជន្តិ នោ ច តេសំ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ តេសំ កុសលា ច ធម្មា ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ឧប្បជ្ជន្តាតិ ។ អាមន្តា ។

(១៧៨) យស្ស អកុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ បច្ឆិមចិត្តសមង្គីនំ តេសំ អកុសលា ធម្មា ឧប្បជ្ជន្តិ នោ ច តេសំ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ តេសំ អកុសលា ច ធម្មា ឧប្បជ្ជន្តិ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស អកុសលា ធម្មា ឧប្បជ្ជន្តាតិ ។ អាមន្តា ។

(១៧៩) យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ ។ បេ ។

(១៨០) យស្ស យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស តត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តីតិ ។

(១៧៧) ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

(១៧៨) ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

(១៧៩) ពួកកុសលធម៌ ធ្លាប់កើតឡើងហើយ ក្នុងទីណា ។ បេ ។

(១៨០) ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។

អគ្គមគ្គសមង្គីនំ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ កុសលា ច ធម្មា ឧប្បជ្ជិត្ថ អកុសលា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថាតិ ។ សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេ[១] តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថ ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ អកុសលា ច ធម្មា ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ឧប្បជ្ជិត្ថ ។

(១៨១) យស្ស យត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថ តស្ស តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ បច្ឆិមចិត្តសមង្គីនំ តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ

---

១ ឱ. សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេតិ ឯត្ថ សុទ្ធាវាសំ ឧប្បជ្ជន្តានន្តិ ទិស្សន្តិយេវ ។

ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺ ពួកសត្វចតុវោការៈ និងបញ្ចវោការៈ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការៈ និងបញ្ចវោការៈ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏ធ្លាប់កើតឡើងហើយដែរ ។

(១៨១) ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្ត នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ

ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ កុសលា ច ធម្មា ឧប្បជ្ជិត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថាតិ ។ សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេ(១) អសញ្ញសត្តានំ តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ឧប្បជ្ជិត្ថ ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ឧប្បជ្ជិត្ថ ។

(១៨២) យស្ស យត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថ តស្ស តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តីតិ ។ បច្ឆិមចិត្តសមង្គីនំ តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ ឥតរេសំ ចតុវោការានំ បញ្ចវោការានំ តេសំ តត្ថ អកុសលា ច ធម្មា ឧប្បជ្ជិត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ

---

១ ឱ. សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេតិ ឯត្ថ សុទ្ធាវាសំ ឧប្បជ្ជន្តានន្តិ ទិស្សន្តិយេវ ។

ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការៈ និងបញ្ចវោការៈ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការៈ និងបញ្ចវោការៈ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏ធ្លាប់កើតឡើងហើយដែរ ។

(១៨២) ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការៈ និងបញ្ចវោការៈ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា

តស្ស តត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថាតិ ។ សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេ អសញ្ញសត្តានំ តេសំ តត្ថ អព្យាកតា ធម្មា ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ អកុសលា ធម្មា ឧប្បជ្ជិត្ថ ឥតរេសំ ចតុវោការានំ តេសំ តត្ថ អព្យាកតា ច ធម្មា ឧប្បជ្ជិស្សន្តិ អកុសលា ច ធម្មា ឧប្បជ្ជិត្ថ ។

(១៨៣) យស្ស កុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ នត្ថិ ។ យស្ស វា បន អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។

(១៨៤) យស្ស កុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ នត្ថិ ។ យស្ស វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស កុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។

(១៨៥) យស្ស អកុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។

ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការៈ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏ធ្លាប់កើតឡើងហើយដែរ ។

(១៨៣) ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

(១៨៤) ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

(១៨៥) ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។

នត្ថិ ។ យស្ស វា បន អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស អកុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។

(១៨៦) យត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថ ។ បេ ។

(១៨៧) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេ តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថ នោ ច តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ អសញ្ញសត្តានំ តេសំ តត្ថ កុសលា ច ធម្មា ន ឧប្បជ្ជិត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ អគ្គមគ្គសមង្គីនំ អរហន្តានំ យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តេសំ តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិស្សន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថ អសញ្ញសត្តានំ តេសំ តត្ថ អកុសលា ច ធម្មា ន ឧប្បជ្ជិស្សន្តិ កុសលា ច ធម្មា ន ឧប្បជ្ជិត្ថ ។

មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

[១៨៦] ពួកកុសលធម៌ មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ។ បេ ។

[១៨៧] ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាន នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់ នៃចិត្តណា នោះ នឹងមិនកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ ក៏នឹងមិនកើតឡើង ក្នុងទីនោះទេ ទាំងពួកកុសលធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។

## ធម្មយមកេ បវត្តិវារស្ស និរោធវារោ

(១៨៨) យស្ស យត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ កុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។

(១៨៩) យស្ស យត្ថ អកុសលា ធម្មា ន ឧប្បជ្ជិត្ថ តស្ស តត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តីតិ ។ ឧប្បជ្ជិស្សន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា ន ឧប្បជ្ជិស្សន្តិ តស្ស តត្ថ អកុសលា ធម្មា ន ឧប្បជ្ជិត្ថាតិ ។ ឧប្បជ្ជិត្ថ ។

ឧប្បាទវារំ និដ្ឋិតំ ។

(១៩០) យស្ស កុសលា ធម្មា និរុជ្ឈន្តិ តស្ស អកុសលា ធម្មា និរុជ្ឈន្តីតិ ។ នោ ។ យស្ស វា បន អកុសលា ធម្មា និរុជ្ឈន្តិ តស្ស កុសលា ធម្មា និរុជ្ឈន្តីតិ ។ នោ ។

(១៩១) យស្ស កុសលា ធម្មា និរុជ្ឈន្តិ តស្ស អព្យាកតា ធម្មា និរុជ្ឈន្តីតិ ។ អរូបេ កុសលានំ ភង្គក្ខណេ តេសំ កុសលា ធម្មា និរុជ្ឈន្តិ នោ ច តេសំ អព្យាកតា ធម្មា និរុជ្ឈន្តិ

ធម្មយមក: បវត្តិវារ: និរោធវារ:

(១៨៨) ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងក្នុងទីនោះឬ ។ នឹងកើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ធ្លាប់កើតឡើងហើយ ។

(១៨៩) ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងក្នុងទីនោះឬ ។ នឹងកើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ធ្លាប់កើតឡើងហើយ ។

ចប់ ឧប្បាទវារ:

(១៩០) ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអកុសល-ធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកកុសលធម៌ របស់បុគ្គលនោះរលត់ដែរឬ ។ មិនមែនទេ ។

(១៩១) ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកកុសលធម៌របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ទេ

បញ្ចវោការេ កុសលានំ ភង្គក្ខណេ តេសំ កុសលា ច ធម្មា និរុជ្ឈន្តិ អព្យាកតា ច ធម្មា និរុជ្ឈន្តិ ។ យស្ស វា បន អព្យាកតា ធម្មា និរុជ្ឈន្តិ តស្ស កុសលា ធម្មា និរុជ្ឈន្តីតិ ។ សព្វេសំ ចវន្តានំ បវត្តេ កុសលវិប្បយុត្តចិត្តស្ស ភង្គក្ខណេ(១) តេសំ អព្យាកតា ធម្មា និរុជ្ឈន្តិ នោ ច តេសំ កុសលា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ កុសលានំ ភង្គក្ខណេ តេសំ អព្យាកតា ច ធម្មា និរុជ្ឈន្តិ កុសលា ច ធម្មា និរុជ្ឈន្តិ ។

(១៩២) យស្ស អកុសលា ធម្មា និរុជ្ឈន្តិ តស្ស អព្យាកតា ធម្មា និរុជ្ឈន្តីតិ ។ អរូបេ អកុសលានំ ភង្គក្ខណេ តេសំ អកុសលា ធម្មា និរុជ្ឈន្តិ នោ ច តេសំ អព្យាកតា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ អកុសលានំ ភង្គក្ខណេ តេសំ អកុសលា ច ធម្មា និរុជ្ឈន្តិ អព្យាកតា ច ធម្មា និរុជ្ឈន្តិ ។ យស្ស វា បន អព្យាកតា ធម្មា និរុជ្ឈន្តិ តស្ស អកុសលា ធម្មា និរុជ្ឈន្តីតិ ។ សព្វេសំ ចវន្តានំ បវត្តេ អកុសលវិប្បយុត្តចិត្តស្ស ភង្គក្ខណេ តេសំ អព្យាកតា ធម្មា និរុជ្ឈន្តិ

១ ឱ. ឯត្ថន្តរេ និរោធសមាបន្នានំ អសញ្ញសត្តានន្តិ ទិស្សន្តិ ។

ឯពួកកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ កាលច្យុត រលត់ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

(១៩២) ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ កាលច្យុត រលត់ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល

នោ ច តេសំ អកុសលា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ អកុសលានំ ភង្គក្ខណេ តេសំ អព្យាកតា ច ធម្មា និរុជ្ឈន្តិ អកុសលា ច ធម្មា និរុជ្ឈន្តិ ។

(១៩៣) យត្ថ កុសលា ធម្មា និរុជ្ឈន្តិ តត្ថ អកុសលា ធម្មា និរុជ្ឈន្តីតិ ។ អាមន្តា ។ យត្ថ វា បន អកុសលា ធម្មា និរុជ្ឈន្តិ តត្ថ កុសលា ធម្មា និរុជ្ឈន្តីតិ ។ អាមន្តា ។

(១៩៤) យត្ថ កុសលា ធម្មា និរុជ្ឈន្តិ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តីតិ ។ អាមន្តា ។ យត្ថ វា បន អព្យាកតា ធម្មា និរុជ្ឈន្តិ តត្ថ កុសលា ធម្មា និរុជ្ឈន្តីតិ ។ អសញ្ញសត្តេ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ នោ ច តត្ថ កុសលា ធម្មា និរុជ្ឈន្តិ ចតុវោការេ បញ្ចវោការេ តត្ថ អព្យាកតា ច ធម្មា និរុជ្ឈន្តិ កុសលា ច ធម្មា និរុជ្ឈន្តិ ។

(១៩៥) យត្ថ អកុសលា ធម្មា និរុជ្ឈន្តិ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តីតិ ។ អាមន្តា ។ យត្ថ វា បន អព្យាកតា ធម្មា និរុជ្ឈន្តិ តត្ថ អកុសលា ធម្មា និរុជ្ឈន្តីតិ ។ អសញ្ញសត្តេ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ នោ ច តត្ថ អកុសលា ធម្មា និរុជ្ឈន្តិ

តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

(១៩៣) ពួកកុសលធម៌ រលត់ ក្នុងទីណា ពួកអកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ រលត់ ក្នុងទីណា ពួកកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។

(១៩៤) ពួកកុសលធម៌ រលត់ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ ក្នុងទីណា ពួកកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្ត តែពួកកុសលធម៌ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

(១៩៥) ពួកអកុសលធម៌ រលត់ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ ក្នុងទីណា ពួកអកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្ត តែពួកអកុសលធម៌ មិនរលត់ ក្នុងទីនោះទេ

ចតុវោការេ បញ្ចវោការេ តត្ថ អព្យាកតា ច ធម្មា និរុជ្ឈន្តិ អកុសលា ច ធម្មា និរុជ្ឈន្តិ ។

(១៩៦) យស្ស យត្ថ កុសលា ធម្មា និរុជ្ឈន្តិ តស្ស តត្ថ អកុសលា ធម្មា និរុជ្ឈន្តីតិ ។ នោ ។ យស្ស វា បន យត្ថ អកុសលា ធម្មា និរុជ្ឈន្តិ តស្ស តត្ថ កុសលា ធម្មា និរុជ្ឈន្តីតិ ។ នោ ។

(១៩៧) យស្ស យត្ថ កុសលា ធម្មា និរុជ្ឈន្តិ តស្ស តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តីតិ ។ អរូបេ កុសលានំ ភង្គក្ខណេ តេសំ តត្ថ កុសលា ធម្មា និរុជ្ឈន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ កុសលានំ ភង្គក្ខណេ តេសំ តត្ថ កុសលា ច ធម្មា និរុជ្ឈន្តិ អព្យាកតា ច ធម្មា និរុជ្ឈន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ តស្ស តត្ថ កុសលា ធម្មា និរុជ្ឈន្តីតិ ។ សព្វេសំ ចវន្តានំ បវត្តេ កុសលវិប្ប-យុត្តចិត្តស្ស ភង្គក្ខណេ(១) តេសំ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ នោ ច តេសំ តត្ថ កុសលា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ កុសលានំ ភង្គក្ខណេ តេសំ តត្ថ អព្យា-កតា ច ធម្មា និរុជ្ឈន្តិ កុសលា ច ធម្មា និរុជ្ឈន្តិ ។

---

១ ឱ. ឯត្ថន្តរេ អសញ្ញសត្តានន្តិ ទិស្សតិ ។

ឯពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[១៩៦] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។

[១៩៧] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ កាលច្យុត រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

## ធម្មយមកេ បវត្តិវារស្ស និរោធវារោ

(១៩៨) យស្ស យត្ថ អកុសលា ធម្មា និរុជ្ឈន្តិ តស្ស តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តីតិ ។ អរូបេ អកុសលានំ ភង្គក្ខណេ តេសំ តត្ថ អកុសលា ធម្មា និរុជ្ឈន្តិ នោ ច តេសំ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ អកុសលានំ ភង្គក្ខណេ តេសំ តត្ថ អកុសលា ច ធម្មា និរុជ្ឈន្តិ អព្យាកតា ច ធម្មា និរុជ្ឈន្តិ ។ យស្ស វា បន យត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ តស្ស តត្ថ អកុសលា ធម្មា និរុជ្ឈន្តីតិ ។ សព្វេសំ ចវន្តានំ បវត្តេ អកុសលវិប្បយុត្តចិត្តស្ស ភង្គក្ខណេ តេសំ តត្ថ អព្យាកតា ធម្មា និរុជ្ឈន្តិ នោ ច តេសំ តត្ថ អកុសលា ធម្មា និរុជ្ឈន្តិ បញ្ចវោការេ អកុសលានំ ភង្គក្ខណេ តេសំ តត្ថ អព្យាកតា ច ធម្មា និរុជ្ឈន្តិ អកុសលា ច ធម្មា និរុជ្ឈន្តិ ។

(១៩៩) យស្ស កុសលា ធម្មា ន និរុជ្ឈន្តិ តស្ស អកុសលា ធម្មា ន និរុជ្ឈន្តីតិ ។ អកុសលានំ ភង្គក្ខណេ តេសំ កុសលា ធម្មា ន និរុជ្ឈន្តិ នោ ច តេសំ អកុសលា ធម្មា ន និរុជ្ឈន្តិ

(១៩៨) ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជន ទាំងអស់នោះ កាលច្យុត រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

(១៩៩) ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ទេ តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន

សព្វេសំ ចិត្តស្ស ឧប្បាទក្ខណេ កុសលវិប្បយុត្តអកុសលវិប្បយុត្តចិត្តស្ស ភង្គក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ កុសលា ច ធម្មា ន និរុជ្ឈន្តិ អកុសលា ច ធម្មា ន និរុជ្ឈន្តិ ។ យស្ស វា បន អកុសលា ធម្មា ន និរុជ្ឈន្តិ តស្ស កុសលា ធម្មា ន និរុជ្ឈន្តីតិ ។ កុសលា ភង្គក្ខណេ តេសំ អកុសលា ធម្មា ន និរុជ្ឈន្តិ នោ ច តេសំ កុសលា ធម្មា ន និរុជ្ឈន្តិ សព្វេសំ ចិត្តស្ស ឧប្បាទក្ខណេ អកុសលវិប្បយុត្តកុសលវិប្បយុត្តចិត្តស្ស ភង្គក្ខណេ និរោធសមាបន្នានំ អសញ្ញសត្តានំ តេសំ អកុសលា ច ធម្មា ន និរុជ្ឈន្តិ កុសលា ច ធម្មា ន និរុជ្ឈន្តិ ។

(២០០) យស្ស កុសលា ធម្មា ន និរុជ្ឈន្តិ តស្ស អព្យាកតា ធម្មា ន និរុជ្ឈន្តីតិ ។ សព្វេសំ ចវន្តានំ បវត្តេ កុសលវិប្បយុត្តចិត្តស្ស ភង្គក្ខណេ(១) តេសំ កុសលា ធម្មា ន និរុជ្ឈន្តិ នោ ច តេសំ អព្យាកតា ធម្មា ន និរុជ្ឈន្តិ សព្វេសំ ឧបបជ្ជន្តានំ បវត្តេ ចិត្តស្ស ឧប្បាទក្ខណេ អរូបេ អកុសលានំ ភង្គក្ខណេ តេសំ កុសលា ច ធម្មា ន និរុជ្ឈន្តិ

---

១ ឱ. ឯត្ថន្តរេ និរោធសមាបន្នានំ អសញ្ញសត្តានន្តិ ន ទិស្សន្តិ ។

ឯពួកកុសលធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកកុសល និងចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈ នៃចិត្ត ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសល-ធម៌ របស់បុគ្គលណា មិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជន ទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកអកុសល និងចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈ នៃចិត្ត ទាំងពួកកុសលធម៌ ក៏មិនរលត់ដែរ ។

